01635553

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារ 10

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងលេខ៖ ០០២/៣១-១០-២០១៩-អវតក/អជតក(០៣)

ចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម Steven BWANA

កាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 01 / 2020
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**ការស្នើសុំដល់ចៅក្រមទាំងប្រាំមួយរូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលជំនុំជម្រះលើសំណុំរឿង ០០២/០១**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. HOLLIS

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Megan HIRST

**សហមេធាវីការពារក្តី ខៀវ សំផន**
គង់ សំអុន
Anta GUISSÉ

**ក្រុមប្រឹក្សាជំនុំជម្រះពិសេស** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានទទួល** "សំណើរបស់លោក ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១" ("សំណើសុំប្តឹងជិតចិត្ត")[1] ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៩។

**បានឃើញ** ចម្លើយតបរៀងៗខ្លួនរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើសុំប្តឹងជិតចិត្ត នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩[2]

**បានឃើញ** ការរៀបចំសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសដើម្បីសម្រេចលើសំណើសុំប្តឹងជិតចិត្ត នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩[3]

**បានឃើញ** ការបង្កើតសំណុំរឿងដាច់ដោយឡែកមួយសម្រាប់ឯកសារនានាទាក់ទងនឹងសំណើសុំប្តឹងជិតចិត្ត និងបានជូនដំណឹងដល់ភាគី និងក្រុមប្រឹក្សាជំនុំជម្រះពិសេស នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០

---

[1] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) សំណើរបស់លោក ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តី នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ឯកសារ 1។

[2] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្តចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ ៥ , សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើរបស់ ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ 6។ ចម្លើយតបទាំងពីរ ត្រូវបានដាក់ស្របតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើសុំបន្ទាន់របស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ពន្យាពេលក្នុងការដាក់ការឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន សុំប្តឹងជិតចិត្ត នៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ ៤ ហើយដែលត្រូវសម្រេចអនុញ្ញាតឲ្យពន្យាពេល។

[3] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) ការជ្រើសតាំងក្រុមប្រឹក្សាជំនុំជម្រះលើសំណើរបស់ ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ 9, សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) ការជ្រើសតាំងក្រុមប្រឹក្សាជំនុំជម្រះលើសំណើរបស់ ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ 7។

**បានឃើញ** អនុលោមតាមវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង នៅពេលដែលភាគីមួយដាក់សំណើសុំប្តឹងជំទាស់ចៅក្រមមួយរូប "ចៅក្រម [រូបនោះ] មានសិទ្ធិដាក់សារណាជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះតាមរយៈប្រធានរបស់ខ្លួន ក្នុងរយៈពេល១០ (ដប់) ថ្ងៃ គិតចាប់ពីថ្ងៃដែលគាត់បានទទួលពាក្យបណ្តឹង"

**ពិចារណា** ថា សំណើសុំប្តឹងជំទាស់ ពាក់ព័ន្ធមិនត្រឹមតែចៅក្រមមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះទេ ប៉ុន្តែពាក់ព័ន្ធជាមួយចៅក្រមទាំងអស់នៃអង្គជំនុំជម្រះ រួមទាំងចៅក្រមប្រធានអង្គជំនុំជម្រះផងដែរ

**ពិចារណា** ថា ចៅក្រមទាំងប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ មានសិទ្ធិដាក់សារណាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាជំនុំជម្រះពិសេស ផ្អែកតាមវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង

**អាស្រ័យហេតុនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស សម្រេច៖**

**ស្នើសុំ** ចៅក្រម គង់ ស្រ៊ីម ចៅក្រម Chandra Nihal JAYASINGHE ចៅក្រម សោម សិរីវឌ្ឍ ចៅក្រម Florence Ndepele MWACHANDE-MUMBA ចៅក្រម ម៉ុង មុនីចរិយា និងចៅក្រម យ៉ា ណារិន ដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសំណើសុំប្តឹងជំទាស់ ទៅក្រុមប្រឹក្សាជំនុំជម្រះពិសេស ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីលិខិតស្នើសុំនេះ។

រាជធានីភ្នំពេញថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ប្រធាន ក្រុមប្រឹក្សាជំនុំជម្រះពិសេស

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

**ស៊ិន រិទ្ធិ** **Steven BWANA**